# តើគ្រីស្ទបរិស័ទ ផឹកស្រាបានដែរឬទេ?

## Can Christians Drink Alcohol?




និពន្ធដោយៈ លោកគ្រូ វែល ណាថាន

រក្សាសិទ្ធិគ្រប់បែបយ៉ាងដោយ៖ លោកគ្រូ វែល ណាថាន
© Copyright 2019 Nathan Wells

ផលិតដោយ៖ សកម្មភាពកម្ពុជា resources@actioncambodia.org
បកប្រែដោយ៖ លោក ឈាង ប៉ូរ៉ា និងលោក ទេព រ៉ូ
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ខែម បូឡុង, លោកស្រី ឡូញ ស្រីរដ្ឋ, លោក ឈាង ប៉ូរ៉ា, លោក វ៉ែល ណាថាន, និងលោក ទេព រ៉ូ
ការប្រើប្រាស់បទព្រះគម្ពីរបរិសុទ្ធ និងជីវិសុទ្ធ និងព្រះគម្ពីរសញ្ញាថ្មីកែសម្រួលឆ្នាំ២០១៤មានការអនុញ្ញាតពីសមាគមព្រះគម្ពីរកម្ពុជា និងរក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល-ដកស្រង់ដោយមានការអនុញ្ញាត។
មានការអនុញ្ញាតការប្រើប្រាស់បទព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ-សញ្ញាថ្មី រក្សាសិទ្ធិ ២០១២ ព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត។

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ © ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ © ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរជីវិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ © ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ © ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

For ordering information please visit:
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ www.plovpit.com

ផ្លូវពិត plovpit.com

# តើគ្រីស្ទបរិស័ទ ផឹកស្រាបានដែរឬទេ?

## Can Christians Drink Alcohol?

និពន្ធដោយៈ លោកគ្រូ វ៉ែល ណាថាន

# មាតិកា

ស្រុកខ្ញុំ ស្រាខ្ញុំ ..........................៣

ស្រាល្អ ឬមិនល្អ? ...................... ៦

ក្រឹត្យវិន័យរបស់មនុស្ស..................១១

តើផ្ទត់គំនិតថា កុំផឹកមកពីណា? .............១៥

ផឹកឬអត់? ..............................១៨

សំណួរ .................................២០

# ស្រុកខ្ញុំ ស្រាខ្ញុំ

មានមនុស្សមួយចំនួនបានលើកឡើងថា «បើមិនចេះផឹកស្រា នោះអ្នកឯងជាមនុស្សអន់» ឬ «បើលើកមិនដាច់មួយកែវ នោះមាននាមថា “អាកំសាកញី”។» ឬក៏ «បើចង់ធ្វើជាបុរសពិត ត្រូវតែចេះផឹកស្រា។» ឬ «បើមកចូលរួមកម្មវិធីមិនផឹកស្រា អញ្ចឹងមកធ្វើអី? ។ល។» ខណៈពេលដែលបុណ្យចូលឆ្នាំខ្មែរខិតជិតមកដល់ យើងឃើញហើយថា នៅស្រុកយើង ស្រាគឺពិតជាពេញនិយមណាស់ ជាពិសេសពេលដែលមានបុណ្យទានឬកម្មវិធីម្តងៗ។ ក្នុងនាមជាគ្រីស្ទបរិស័ទ តើឲ្យយើងត្រូវឆ្លើយតបយ៉ាងដូចម្តេច ពេលដែលមានកម្មវិធីជួបជុំបងប្អូនម្តងៗ ដែលមិនមែនជាអ្នកជឿលើព្រះយេស៊ូវ ហើយពួកគាត់មានការទទួលទានភេសជ្ជៈដែលមានជាតិអាល់កុល? តើព្រះគម្ពីរបានរៀបរាប់យ៉ាងដូចម្តេចខ្លះទាក់ទង់នឹងស្រា? ជាពិសេសទាក់ទងនឹងគ្រីស្ទបរិស័ទជាមួយនឹងស្រា?

## ប្រវត្តិស្រា

ភេសជ្ជៈដែលមានជាតិអាល់កុលមានតាំងពីយូរយាណាស់មកហើយ។ លោកណូអេ គឺជាបុគ្គលដំបូងដែលបានស្រវឹងស្រា ដែលមានចែងទុកក្នុងព្រះគម្ពីរ (លោកុប្បត្តិ ៩:២១) ប៉ុន្តែគាត់មិនមែនជាបុគ្គលដំបូងគេបង្អស់ដែលបានស្រវឹង

ស្រាជោកខ្លួននោះទេ ដ្បិតចំណេះដឹងនៃរបៀបបិតស្រាត្រូវបានបង្រៀនតកូនតចៅអស់ជាច្រើនជំនាន់ណាស់មកហើយ។

សំណួរគឺថា *តើគ្រីស្ទបរិស័ទអាចទទួលទានភេសជ្ជៈដែលមានជាតិអាល់កុលបានដែរឬទេ?* ជាដំបូង យើងខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា សំណួរគឺមិនមែនសួរថា *តើគ្រីស្ទបរិស័ទអាចផឹកស្រារហូតដល់ស្រវឹងបានមែនឬ?* នោះទេ។ ព្រះគម្ពីរបានលើកឡើងយ៉ាងច្បាស់លាស់ ដែលយើងមិនគួរមើលរំលងនោះទេ គឺថាយើងមិនត្រូវផឹករហូតដល់ស្រវឹងបានឡើយៈ

អេភេសូរ ៥:១៨ បានចែងថា *«កុំឲ្យស្រវឹងស្រា ដែលនាំឲ្យព្រើលចិត្តឡើយ តែចូរឲ្យបានពេញជាព្រះវិញ្ញាណវិញ»*។

យើងខ្ញុំសង្ឃឹមថា ខគម្ពីរមួយនេះបានបញ្ជាក់យ៉ាងច្បាស់ ហើយល្មមគ្រប់គ្រាន់ហើយត្រង់ថា *«កុំឲ្យស្រវឹងស្រា»!*

ប៉ុន្តែ ក៏នៅមានមនុស្សមួយចំនួនផ្សេងទៀត ដែលបានលើកឡើងថា ដាច់ខាត! គ្រីស្ទបរិស័ទមិនគួរទទួលទានរាល់ភេសជ្ជៈដែលមានជាតិអាល់កុលណាមួយបាននោះទេ។ តើផ្នត់គំនិតបែបនេះកើតចេញមកពីប្រភពណា? តើវាមានប្រភពចេញពីព្រះគម្ពីរ ឬក៏មកពីច្បាប់នៃមនុស្សសាសនានិយមដែលបានបង្កើតឡើង?

ពិតណាស់! ព្រះគម្ពីរបានលើកឡើងអំពីក្រុមមនុស្សដែលត្រូវតមពីការទទួលទានភេសជ្ជៈដែលមានជាតិអាល់កុល។ ព្រះជាម្ចាស់បានបង្គាប់មិនឲ្យពួកសង្ឃសាសន៍អ៊ីស្រាអែលផឹកភេសជ្ជៈដែលមានជាតិអាល់កុលណាមួយឡើយ (លេវីវិន័យ ១០:៩)។ ហើយចំពោះបុគ្គលណាដែលមានបន់បំណន់ន៉ាសារីត ក៏ពួកគាត់មិនត្រូវទទួលទានភេសជ្ជៈដែលមានជាតិអាល់កុលបាន

ដែរ (ជនគណនា ៦:២-៤)។ ប៉ុន្តែ ព្រះគម្ពីរ (មិនថាក្នុងព្រះគម្ពីរសញ្ញាចាស់ ឬក៏សញ្ញាថ្មី) មិនមានលើកឡើងនូវបទបញ្ជាចំពោះអស់អ្នកដែលដើរតាមព្រះជាម្ចាស់ថា ពួកគាត់មិនត្រូវផឹកភេសជ្ជៈដែលមានជាតិអាល់កុលដាច់ខាតនោះទេ។ តាមពិតទៅ ព្រះគម្ពីរបានបង្រៀននូវចំណុចដែលផ្ទុយពីនេះទាំងស្រុង!

# ស្រាលួ ឬមិនលួ?

ព្រះគម្ពីរបានលើកឡើងអំពីភេសជ្ជៈដែលមានជាតិអាល់កុលប្រមាណជាង ២០០ដង។ ១៦%នៃចំនួន ២០០ដងនោះគឺអវិជ្ជមាន (ការព្រមានទាស់នឹងការស្រវឹង ហើយនិងគ្រោះថ្នាក់នៃ ភេសជ្ជៈដែលមានជាតិអាល់កុល ដែលអ្នកផឹកទំនងនឹងប្រឈមមុខជាមួយ។ល។) ៥៩%នៃចំនួន២០០ដងនោះគឺវិជ្ជមាន (តំណាងឲ្យព្រះពររបស់ព្រះជាម្ចាស់ សម្រាប់ប្រើប្រាស់ពេលថ្វាយបង្គំ។ល។) ហើយ២៥%នៃចំនួន២០០ដងនោះគឺអព្យាក្រឹត្យដោយមិនមានភាពលម្អៀងវិជ្ជមាន ឬក៏អវិជ្ជមានបែបចាក់ខ្សែឡើយ (មានគេមូលបង្ខូចយ៉ាងខុសឆ្គងដែលទាក់ទងនឹងការស្រវឹង ឬក៏សម្បថនៃការតមមិនផឹក។ល។)។

## ស្រាល្អ

ព្រះគម្ពីរបានបង្រៀនជារឿយៗថា យើងគួរមានភាពអរសប្បាយក្នុងការទទួលភេសជ្ជៈដែលមានជាតិអាល់កុលទៅវិញទេតើ។ ពេលដែលលោក អ័ប្រាហាំ បានត្រឡប់មកវិញពីការដែលទើបតែទទួលបានជ័យជម្នះក្នុងការរំដោះលោក ឡុតចេញពីអ្នកចាប់គាត់ យើងឃើញថាលោក ម៉ិលគីស្សាដែក ជាសង្ឃរបស់ព្រះដ៏

ខ្ពស់បំផុត បានមកជួបលោក អ័ប្រាហាំ ដោយនាំមកនូវនំប៉័ង និងស្រា (លោកុប្បត្តិ ១៤:១៨)។ ព្រះជាម្ចាស់បានបង្គាប់ដល់សាសន៍អ៊ីស្រាអែល ដែលមិនអាចធ្វើដំណើរទៅព្រះវិហារ ដើម្បីថ្វាយបង្គំ ឲ្យពួកគាត់យកដង្វាយរបស់ពួកគាត់ទៅប្រើប្រាស់ក្នុងការធ្វើពិធីជប់លៀងនៅផ្ទះ។ ហើយក្នុងចំណែកមួយនៃពិធីជប់លៀងនោះក៏រួមមានទាំងស្រា និងភេសជ្ជៈដែលមានជាតិអាល់កុលផងដែរ!

ចោទិយកថា ១៤:២៦ *«ហើយនឹងចំណាយប្រាក់នោះ ទិញអ្វីៗតាមប្រាថ្នាបាន ទោះជាគោ ឬចៀម ឬស្រាទំពាំងបាយជូរ ឬគ្រឿងផឹកណា ឬរបស់អ្វីក៏ដោយ ដែលឯងគាប់ចិត្ត រួចនឹងបរិភោគនៅចំពោះព្រះយេហូវ៉ា ជាព្រះនៃឯងនៅទីនោះហើយត្រូវអរសប្បាយឡើង ព្រមទាំងពួកគ្រួឯងជាមួយនឹងឯងផង»*។

លើសពីការប្រាប់ឲ្យសាសន៍អ៊ីស្រាអែលតមភេសជ្ជៈដែលមានជាតិអាល់កុល ព្រះជាម្ចាស់បែរជាលើកទឹកចិត្តឲ្យពួកគាត់ទទួលទានស្រានៅពេលមានពិធីជប់លៀងទៀតផង។

ក្នុងការថ្វាយយញ្ញបូជាក្នុងព្រះគម្ពីរសញ្ញាចាស់ ស្រាក៏ជាផ្នែកដ៏សំខាន់មួយផងដែរសម្រាប់សាសន៍អ៊ីស្រាអែល ពីព្រោះព្រះជាម្ចាស់បានបង្គាប់ឲ្យយកស្រាធ្វើជាយញ្ញបូជាមួយដែរ (និក្ខមនំ ២៩:៤០ និងលេវីវិន័យ ២៣:១៣)។

ព្រះគម្ពីរបានលើកឡើងម្តងហើយម្តងទៀតថា ស្រាគឺជាអ្វីមួយដែលល្អ ហើយយើងក៏គួរមានការអរសប្បាយនឹងវាផងដែរ។ វាក៏ជាអ្វីមួយដែលព្រះជាម្ចាស់បានប្រទានពរលើផ្នែកនោះផងដែរ! វាជាអ្វីមួយដែលព្រះជាម្ចាស់បានប្រទានមក *«ដែលនាំឲ្យចិត្តមនុស្សបានសប្បាយ»* (ទំនុកតម្កើង ១០៤:១៤-១៥)។ ហើយស្រាក៏តំណាងឲ្យជីវិតអស់កល្បជានិច្ចដែលមកពីព្រះជាម្ចាស់ផងដែរ ជាអ្វីមួយដែលយើងត្រូវ *«ទិញ»* ពីព្រះជាម្ចាស់ *«ឯអ្នកដែលគ្មានប្រាក់អើយ!*

*ចូរមកទិញ ហើយបរិភោគទៅ!»* (អេសាយ ៥៥:១-២)។ ហើយនៅក្នុងនគររបស់ព្រះជាម្ចាស់នាពេលអនាគតនឹងមានស្រាជាច្រើននៅឯពិធីជប់លៀងដែលព្រះជាម្ចាស់នឹងបម្រើពួករាស្ត្ររបស់ទ្រង់ ហើយព្រះអង្គក៏បានសន្យាផងដែរថា ពេលដែលទ្រង់ស្តារសាសន៍អ៊ីស្រាអែលឡើងវិញ នោះពួកគាត់ *«នឹងដាំចំការទំពាំងបាយជូរ ក៏នឹងផឹកស្រាទំពាំងបាយជូរ ជាផលពីចំការនោះ»* (អេសាយ ២៥:៦-៨ និងអេម៉ុស ៩:១៣-១៤)។

នេះឯងជាមូលហេតុដែលយើងខ្ញុំមិនប្រើប្រាស់ពាក្យ «គ្រឿងស្រវឹង» ព្រោះពាក្យនោះលើកបញ្ជិតបញ្ជៀងថា ព្រះជាម្ចាស់បានបង្កើតស្រាមក ដើម្បីធ្វើឲ្យយើងស្រវឹងនោះទេ។ វាក៏លើកបញ្ជិតបញ្ជៀងផងដែរថា បើលោកអ្នកផឹកនោះមានន័យថាលោកអ្នកកំពុងតែចង់ស្រវឹងហើយ។ ប៉ុន្តែ នោះមិនមែនជាអ្វីដែលព្រះជាម្ចាស់បានបង្កើតមកទាក់ទងនឹងស្រាឡើយ។ ប្រាកដណាស់! ស្រាអាចធ្វើឲ្យយើងស្រវឹងបាន ប៉ុន្តែព្រះជាម្ចាស់បានបង្កើតវាមក ដើម្បីធ្វើឲ្យការអបអរសាទររបស់យើងកាន់តែប្រសើរឡើងៗថែមទៀត។ ជាទូទៅ មនុស្សម្នាមិននាំគ្នាផឹកស្រានៅឯពិធីបុណ្យសពនោះទេ លុះត្រាតែពួកគាត់ព្យាយាមផឹករហូតដល់ស្រវឹង ដើម្បីបំភ្លេចបញ្ហារបស់ពួកគាត់ (ដែលនោះគឺជាអំពើបាប!)។ ប៉ុន្តែ ការផឹកស្រាឲ្យត្រឹមត្រូវគឺមិនមែន ដើម្បីបំភ្លេចនោះឡើយ តែដើម្បីធ្វើឲ្យយើងកាន់តែមានអំណរប្រសើរឡើងជាងមុន។ នេះឯងជាមូលហេតុដែលមានប្រពៃណីជាច្រើនពេញនិយមផឹកស្រាក្នុងពិធីមង្គលការ! ស្រាធ្វើឲ្យយើងកាន់តែមានសមត្ថភាពក្នុងការមានភាពអរសប្បាយពេលដែលយើងអបអរសាទរ ហើយនេះឯងជារបៀបមួយដែលយើងឃើញពីការប្រើប្រាស់ក្នុងព្រះបន្ទូលបែបវិជ្ជមាន។ ប៉ុន្តែ ពេលដែលយើងមិនផឹកស្រាក្នុងរបៀបដែលព្រះជាម្ចាស់បានគ្រោងទុក ហើយ

យើងផឹក ដើម្បីឲ្យស្រវឹង នោះកម្មវិធីរបស់យើងនឹងក្លាយជាកម្មវិធីដែលខូចខាត ហើយហិនហោចទៅវិញ។ ការផឹកស្រារហូតដល់ស្រវឹងគឺជាអំពើបាប ប៉ុន្តែការផឹកក្នុងរបៀបដែលព្រះជាម្ចាស់បានគ្រោងទុកគឺមិនមែនជាអំពើបាបនោះទេ ប៉ុន្តែគឺជាអំណោយទានពីព្រះអង្គ ដើម្បីឲ្យយើងមានភាពសប្បាយរីករាយវិញទេតើ។

## ស្រាមិនល្អ

ព្រះគម្ពីរក៏បានលើកឡើងបែបអវិជ្ជមានផងដែរអំពីស្រា និងការទទួលទានភេសជ្ជៈដែលមានជាតិអាល់កុល ប៉ុន្តែគ្រប់ពេលគឺទាក់ទងនឹងការស្រវឹងជោកខ្លួន៖

*«កុំឲ្យនៅកណ្ដាលពួកអ្នកប្រមឹកស្រា ឬក្នុងពួកល្មោភស៊ីឡើយ ដ្បិតមនុស្សប្រមឹក នឹងមនុស្សល្មោភនឹងទៅជាក្រ ហើយសេចក្ដីងុយងោកនឹងនាំឲ្យស្លៀកពាក់កណ្ដាច»* (សុភាសិត ២៣:២០-២១)។

*«ឯស្រាទំពាំងបាយជូរ ជារបស់បញ្ឆោតមើលងាយ ហើយគ្រឿងស្រវឹងបង្កើតការឡូឡា អ្នកណាដែលវង្វេងដោយគ្រឿងទាំង២នោះ ឈ្មោះថាគ្មានប្រាជ្ញា»* (សុភាសិត ២០:១ ហើយសូមអានបន្ថែមក្នុងកណ្ឌគម្ពីរ អេសាយ ២៨:១-៧ និងយ៉ូអែល ១:៥)។

ហើយខណៈពេលដែលយើងមើលទៅជុំវិញសង្គមយើង យើងក៏ឃើញពីភាពត្រឹមត្រូវនៃប្រាជ្ញារបស់ព្រះជាម្ចាស់ផងដែរ។ ការស្រវឹងស្រាបានបំផ្លាញជីវិតអ្នកផឹកជាច្រើននាក់។ វាមិនគ្រាន់តែជះឥទ្ធិពលលើបុគ្គលដែលផឹកនោះទេ ប៉ុន្តែការបំផ្លាញនោះក៏ជ្រាបចូលទៅកាន់ជីវិតអស់អ្នកដែលនៅជុំវិញពួកគាត់ផងដែរ ឧទាហរណ៍៖ ដៃគូរជីវិត កូនចៅ និងសាច់ញាតិ ក៏ដូចជាអ្នកជិតខាងទៀត

ផង។ ជាទូទៅ មនុស្សពីរនាក់ក្នុងចំណោមមនុស្សបីនាក់នឹងមានចំណែកក្នុងគ្រោះថ្នាក់ចរាចរណ៍ដែលកើតមានឡើងដោយសារការបើកបរក្រោមឥទ្ធិពលនៃសារជាតិអាល់កុល មិនថាកើតឡើងដោយសារបើកបរដោយសារស្រវឹងដោយខ្លួនឯង ឬក៏ត្រូវបានអ្នកស្រវឹងដែលកំពុងបើកបរមកបុកក៏ដោយ (http://www-nrd.nhtsa.dot.gov/Pubs/812013.pdf)។ ការផឹកស្រាលើសកម្រិតបាននាំឲ្យមានមនុស្សប្រមាណជាង៣លាននាក់ស្លាប់ជាប្រចាំឆ្នាំលើពិភពលោកនេះទាំងមូល (https://www.statista.com/statistics/367890/alcohol-related-deaths-facts-worldwide/)។ ក្នុងនាមជាគ្រីស្ទបរិស័ទ យើងមិនគួរផឹករហូតដល់ស្រវឹងឡើយ ជាដំបូងពីព្រោះព្រះជាម្ចាស់បានបង្គាប់មិនឲ្យយើងធ្វើបែបនោះ ហើយក៏ពីព្រោះយើងក៏ឃើញផងដែរតាមរយៈការសង្កេតមើលថាបញ្ញត្តិរបស់ព្រះជាម្ចាស់គឺល្អ ហើយត្រឹមត្រូវ ដ្បិតការស្រវឹងមិនគ្រាន់តែបំផ្លាញជីវិតយើងផ្ទាល់ខ្លួនប៉ុណ្ណោះនោះឡើយ ប៉ុន្តែថែមទាំងបំផ្លាញជីវិតរបស់អស់អ្នកដែលយើងស្រឡាញ់នៅជុំវិញខ្លួនផងដែរ។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺ៖ កុំឲ្យយើងផឹករហូតដល់ស្រវឹង។

# ក្រឹត្យវិន័យរបស់មនុស្ស

ប៉ុន្តែ ជាថ្មីម្តងទៀត ព្រះគម្ពីរមិនដែលហាមប្រាមឲ្យអស់អ្នកដែលដើរតាមព្រះជាម្ចាស់មិនឲ្យផឹកភេសជ្ជៈដែលមានជាតិអាល់កុលនោះទេ។ មានតែមនុស្សក្នុងក្រុមមួយចំនួនក្រោមក្រឹត្យវិន័យរបស់លោក ម៉ូសេ ប៉ុណ្ណោះ។ ហើយក្រៅពីហ្នឹងគឺព្រះគម្ពីរសញ្ញាថ្មីមិនបានហាមប្រាមនរណាម្នាក់មិនឲ្យផឹកនោះឡើយ។ តាមពិតទៅសាវ័ក ប៉ុល ថែមទាំងបានសរសេរទៅកាន់លោក ធីម៉ូថេ ហើយបានប្រាប់គាត់ថា ពុំគ្រាន់តែផឹកទឹកប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏គួរតែផឹកស្រាបន្តិចផងដើម្បីជួយរោគដែលមានជាញយៗ (១ធីម៉ូថេ ៥:២៣)។ ចំណុចនេះបង្ហាញថាលោក ធីម៉ូថេ បានជ្រើសរើសតមស្រាក្នុងអំឡុងពេលណាមួយ ប៉ុន្តែនោះជាជម្រើសផ្ទាល់ខ្លួនរបស់គាត់ ហើយក៏ជាជម្រើសដែលសាវ័ក ប៉ុល មិនបានលើកទឹកចិត្តឲ្យធ្វើ។ ហើយខគម្ពីរនានាជាច្រើនទាក់ទងនឹងភេសជ្ជៈដែលមានជាតិអាល់កុលក្នុងព្រះគម្ពីរគឺសុទ្ធតែវិជ្ជមាន ក្នុងលក្ខណៈបែបដែលព្រះជាម្ចាស់បានប្រទានឲ្យយើងសម្រាប់មានការអរសប្បាយ។ ប៉ុន្តែ យើងក៏មិនគួរផឹកឲ្យហួសហេតុពេកហួសកម្រិតនោះដែរ ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់បានលើកឡើងយ៉ាងច្បាស់ថា ការផឹកជ្រុលដល់ថ្នាក់ស្រវឹងជោកខ្លួនគឺមិនមែនជាព្រះហឫទ័យរបស់ព្រះអង្គសម្រាប់ជីវិតរស់នៅរបស់យើងនោះឡើយ។

# ស្រាខុសគ្នា?

មានមនុស្សមួយចំនួនប្រកែកថា ស្រាដែលបានផលិតឡើងនៅសម័យកាលព្រះគម្ពីរគឺមិនដូចស្រាដែលបានផលិតឡើងនាពេលសព្វថ្ងៃនេះទេ។ ការគិតបែបនោះក៏មានសេចក្ដីពិតខ្លះៗផងដែរ។ ភេសជ្ជៈដែលមានជាតិអាល់កុលបែបជា «ស្រាបៀរ» នៅសម័យបុរាណមានលក្ខណៈដូចជាត្រប៉ែជាងស្រាដែលមានផលិតឡើងនៅបច្ចុប្បន្នកាលនេះ។ ហើយជាតិអាល់កុលក៏ទំនងជាមានតិចជាងនៅសម័យនោះក្នុងស្រា បើប្រៀបធៀបទៅនឹងស្រាដែលមានសព្វថ្ងៃនេះ។ ប៉ុន្តែ ស្នាដៃនៃការបិតស្រាហាក់បីដូចជាមានវ័យចំណាស់ស្មើនឹងមនុស្សជាតិទៅទៀត។ ហើយការផឹកជ្រុលហួសហេតុ ដើម្បីឲ្យបានស្រវឹងក៏ចាស់ស្មើគ្នាផងដែរ។ ចំណុចពិតគឺ៖ វាមិនមែនជាស្អីទេ បើស្រាមានជាតិអាល់កុលច្រើន ឬតិចសព្វថ្ងៃនេះពេលប្រៀបធៀបទៅនឹងសម័យកាលព្រះគម្ពីរ ព្រោះព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺច្បាស់ណាស់ហើយត្រង់ថា កុំឲ្យស្រវឹងស្រាឡើយ។ ប្រសិនបើភេសជ្ជៈណាមួយមានជាតិអាល់កុលច្រើន ក្នុងនាមយើងជាគ្រីស្ទបរិស័ទដែលមានចិត្តប្រាថ្នាចង់ដើរតាមព្រះគ្រីស្ទ នោះយើងពុំគួរផឹកច្រើនពេកអី។ ដូចគ្នាផងនោះដែរ អាស្រ័យលើទម្ងន់ និងការដែលរូបកាយរបស់លោកអ្នកអាចបម្លែងអាហារឲ្យទៅជាថាមពលលឿនប៉ុណ្ណា ការនោះក៏អាចជួយប្រាប់ថា លោកអ្នកអាច ឬក៏មិនអាចទទួលទានភេសជ្ជៈដែលមានជាតិអាល់កុលច្រើនប៉ុណ្ណាដែរ មុនលោកអ្នកចាប់ផ្ដើមស្រវេស្រវាវង្វេងស្មារតីដោយការស្រវឹង។ ប៉ុន្តែ ចំណុចនោះគឺនៅតែដូចគ្នាដដែល ទោះជាយ៉ាងណាក៏ដោយ ក៏យើងមិនត្រូវផឹកដល់ស្រវឹងដល់ថ្នាក់ឆ្កែលិឍមាត់នោះដែរ។ តាមរយៈប្រវត្តិសាស្ត្រ យើងដឹងហើយថា ការផឹករហូតដល់ស្រវឹងគឺជាទង្វើមួយដែលមនុស្សលោកយើងធ្វើម្ដងហើយ

ម្តងទៀត ហើយឈានដល់ដំណាក់នៃការស្រវឹងគឺកើតឡើងតាមរយៈការផឹកគ្រឿងភេសជ្ជៈដែលមានជាតិអាល់កុល។

## ចូរប្រុងប្រយ័ត្នក្នុងការបន្ថែមវិន័យ

រាល់ពេលណាដែលលោកអ្នកត្រូវការប្រើប្រាស់ភស្តុតាងបន្ថែមលើអ្វីដែលមានចែងក្នុងព្រះគម្ពីររួចហើយ ដើម្បីជាអំណះអំណាងរបស់លោកអ្នក នោះមានន័យថា លោកអ្នកកំពុងតែគិតថាព្រះគម្ពីរមិនមានលក្ខណៈច្បាស់លាស់ ហេតុដូច្នេះហើយបានជាលោកអ្នកត្រូវការព័ត៌មានបន្ថែមក្រៅពីព្រះគម្ពីរ។ ហើយនេះគឺជាករណីចំពោះអស់អ្នកដែលបានបង្រៀនថា ដាច់ខាត! គ្រីស្ទបរិស័ទមិនគួរផឹកស្រា។ វាគឺជាគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរក្នុងការបន្ថែមលើព្រះបន្ទូល ហើយបានបង្កើតវិន័យសម្រាប់គ្រីស្ទបរិស័ទឲ្យពួកគាត់ត្រាប់តាម ដែលមិនមានចែងក្នុងព្រះគម្ពីររបស់ព្រះជាម្ចាស់ទាល់តែសោះ។ ផ្ទុយពីនោះ យើងត្រូវតែប្រាថ្នាដើរតាមព្រះគ្រីស្ទទាំងស្រុង ដោយផ្តល់សេរីភាពចំពោះកន្លែងដែលទ្រង់ផ្តល់សេរីភាព ហើយឈប់នៅកន្លែងណាដែលព្រះអង្គឲ្យឈប់។ សាវ័ក ប៉ុល បានសរសេរថា «*ដូច្នេះ កុំឲ្យអ្នកណានិន្ទាអ្នករាល់គ្នា ពីរឿងចំណីអាហារ ឬគ្រឿងផឹក ឬពីរឿងថ្ងៃបុណ្យ ថ្ងៃចូលខែ ឬថ្ងៃឈប់សម្រាកឡើយ សេចក្តីទាំងនេះជាស្រមោលនៃការដែលត្រូវមក តែតួរូបអង្គនោះ គឺជាព្រះគ្រីស្ទ កុំឲ្យអ្នកណាបញ្ឆោតយករង្វាន់របស់អ្នករាល់គ្នា តាមតែចិត្តឡើយ ដោយគេប្រព្រឹត្តបែបសុភាព ទាំងថ្វាយបង្គំពួកទេវតា ទាំងសៀតស៊កចូលទៅក្នុងការ ដែលខ្លួនមើលមិនឃើញ ហើយមានចិត្តប៉ោងឡើង ដោយគំនិតខាងសាច់ឈាមគេនោះ គេមិនកាន់ជាប់តាមសិរសាទេ ដែលដោយសារសិរសានោះ រូបកាយទាំងមូលបានមានកម្លាំង ហើយជាប់*

*គ្នា ដោយសារសន្លាក់ នឹងសរសៃទាំងប៉ុន្មាន ឲ្យបានចម្រើនឡើង ដោយសេចក្ដីចម្រើនរបស់ព្រះ។ ដូច្នេះ បើសិនជាអ្នករាល់គ្នាបានស្លាប់ទៅ ជាមួយនឹងព្រះគ្រីស្ទ ខាងឯបឋមសិក្សារបស់លោកីយ៍នេះមែន នោះតើហេតុអ្វីបានជាអ្នករាល់គ្នា ធ្វើដូចជារស់នៅជាប់ក្នុងលោកីយ៍នៅឡើយ ដោយចុះចូលនឹងបញ្ញត្តិទាំងប៉ុន្មានវិញ ដូចជាថា កុំឲ្យកាន់ កុំឲ្យភ្លក់ កុំឲ្យពាល់ឲ្យសោះ គឺតាមសេចក្ដីហាមប្រាម នឹងសេចក្ដីបង្រៀនរបស់មនុស្ស ដែលសេចក្ដីទាំងនោះតែងតែវិនាសបាត់ទៅ ដោយការប្រើប្រាស ជាសេចក្ដីដែលមើលទៅដូចជាមានទំនងមែន ដោយមានការថ្វាយបង្គំស្ម័គ្រពីចិត្ត ហើយមានសេចក្ដីសុភាព ឥតប្រណីរូបសាច់ តែគ្មានប្រយោជន៍នឹងទប់ទល់សេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាមឡើយ»* (កូឡូស ២:១៦-២៣ សូមអានបន្ថែមនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ៤:៣)។

រឿងនេះមិនគួរដូច្នោះទេ ដ្បិតព្រះគម្ពីរមានចែងយ៉ាងច្បាស់ទាក់ទងនឹងការដែលគ្រីស្ទបរិស័ទអាចទទួលទានភេសជ្ជៈដែលមានជាតិអាល់កុលឬក៏អត់។ ព្រះគម្ពីរមិនបានបញ្ជាក់អំពីចំនួនភាគរយនៃជាតិអាល់កុលក្នុងស្រា ឬក៏ភេសជ្ជៈដែលមានជាតិអាល់កុល ពីព្រោះវាមិនសំខាន់ទេ! គ្រីស្ទបរិស័ទមានសេរីភាពក្នុងការទទួលទានភេសជ្ជៈដែលមានជាតិអាល់កុលបាន។

ច្បាស់ណាស់! គ្រីស្ទបរិស័ទអាចទទួលទានស្រា និងភេសជ្ជៈដែលមានជាតិអាល់កុលបាន។

បង្គាប់គឺមិនមែនឲ្យយើងតមនោះទេ ប៉ុន្តែឲ្យយើងអនុវត្តការចេះគ្រប់គ្រងលើខ្លួនឯង ដែលនេះគឺជាផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ (កាឡាទី ៥:២២)។

# តើផ្នត់គំនិតថា កុំផឹកមកពីណា?

សំណួរគឺថា តើផ្នត់គំនិតដែលថា គ្រីស្ទបរិស័ទមិនអាចទទួលទានភេសជ្ជៈដែលមានជាតិអាល់កុលបាន កើតចេញមកពីប្រភពណា?

ផ្នត់គំនិតដែលថា គ្រូគង្វាលមិនគួរផឹកស្រាគឺជាផ្នត់គំនិតដ៏ចាស់មួយ។ លោកគ្រូ ធើរធូលាន (Tertullian ដែលបានស្លាប់នៅឆ្នាំ២២០នៃគ.ស.) បានបង្រៀនថា គ្រូគង្វាលគួរគោរពតាមក្រឹត្យវិន័យនៃការតមស្រាដែលព្រះជាម្ចាស់បានដាក់លើលោក អើរ៉ុន និងពួកសង្ឃ (http://www.earlychristianwritings.com/text/tertullian33.html)។ ប៉ុន្តែ បើគ្រូគង្វាលគ្រីស្ទបរិស័ទត្រូវតែគោរពតាមក្រឹត្យវិន័យមួយនេះដែលបានដាក់លើពួកសង្ឃ នោះមានន័យថា ពួកគាត់ក៏ត្រូវតែគោរពតាមនូវរាល់ក្រឹត្យវិន័យផ្សេងៗទៀតទាំងអស់ផងដែរ។ យើងមិនត្រូវវែកញែកក្រឹត្យវិន័យនៅក្នុងក្រឹត្យវិន័យដោយគ្រាន់តែជ្រើសរើសយកក្រឹត្យវិន័យនេះ ឬក៏ក្រឹត្យវិន័យនោះ ដើម្បីយកមកគោរពតាមបានឡើយ (បើគ្រូគង្វាលមិនអាចទទួលទានស្រាដូចជាសង្ឃណាម្នាក់ នោះក៏មានន័យថា គាត់ក៏មិនអាចប៉ះមនុស្សស្លាប់ កោរជើងសក់នៃពុកមាត់របស់ខ្លួន រៀបការជាមួយនឹងស្ត្រីមេ

ម៉ាយ។ល។ សូមអានបន្ថែមកណ្ឌគម្ពីរលេវីវិន័យជំពូក២១)។ ព្រះជាម្ចាស់បានប្រទានក្រឹត្យវិន័យដល់សាសន៍អ៊ីស្រាអែល ហើយពួកគាត់មិនអាចជ្រើសរើសតាមតែចិត្តថានឹងគ្រាប់តាមចំណុចមួយណា ឬក៏មិនគ្រាប់តាមចំណុចមួយណាក៏បាននោះទេ។ ព្រះអង្គបានបង្គាប់ឲ្យពួកគាត់គ្រាប់តាមគ្រប់ចំណុចទាំងអស់ ហើយបើពួកគាត់បរាជ័យក្នុងការមិនគ្រាប់តាមចំណុចណាមួយ នោះមានន័យថាពួកគាត់មិនបានគ្រាប់តាមរាល់គ្រប់ចំណុចទាំងអស់ហើយ (យ៉ាកុប ២:១០)។ ហើយយើងក៏ដឹងផងដែរថា ការនិយាយថាយើងគួរតែគ្រាប់តាមក្រឹត្យវិន័យនៅក្នុងសញ្ញាចាស់ក៏មិនមានភាពស៊ីគ្នានឹងការដើរតាមព្រះគ្រីស្ទ ដ្បិតយើងមិនស្ថិតនៅក្រោមក្រឹត្យវិន័យទៀតឡើយ (កាឡាទី ៥:១៨)។

ប៉ុន្តែ ផ្ទត់គំនិតដែលថា គ្រីស្ទបរិស័ទគ្រប់ៗរូបគួរតែតមពីការផឹកស្រាគឺតាមពិតទៅជាគំនិតដ៏ថ្មីមួយទេ។ ហើយការនេះកើតចេញមកពីប្រទេសអាម៉េរិក។ ហើយនេះឯងដែលជាមូលហេតុដែលមានក្រុមជំនុំជាច្រើននៅក្នុងប្រទេសកម្ពុជាបង្រៀនថា គ្រីស្ទបរិស័ទមិនគួរទទួលទានស្រាបានឡើយ ហើយគួរប្រើប្រាស់ទឹកទំពាំងបាយជូរពេលធ្វើពិធីលៀងព្រះអម្ចាស់ជាជាងប្រើប្រាស់ស្រា (បើយោងតាមព្រះគម្ពីរ គឺស្រា ព្រោះសាវ័ក ប៉ុល បានសរសេរថ្កោលទោសក្រុមជំនុំកូរិនថូសដោយសារពួកគាត់ស្រវឹងជោកខ្លួន ខណៈពេលដែលពួកគាត់ធ្វើពិធីលៀងព្រះអម្ចាស់ក្នុងកណ្ឌគម្ពីរ កូរិនថូស ១១:២១)។ ដំបូងឡើយ ក្រុមចលនាបញ្ឈប់ភេសជ្ជៈដែលមានជាតិអាល់កុលនៅប្រទេសអាម៉េរិក (Temperance Movement in America) ជំទាស់នឹងការបិតស្រាយកមកធ្វើជាភេសជ្ជៈ ដែលមានដូចជា វីស្គី រ៉ុំ និងស្រាបារ (whisky, rum, and brandy) ប៉ុន្តែ មិនយូរមិនឆាប់ពួកគាត់ក៏បានចាប់ផ្តើមបង្រៀនថា យើងគួរតែតមពីការទទួលទានភេសជ្ជៈដែល

មានជាតិអាល់កុលគ្រប់ប្រភេទ ដែលនោះគឺជាការឆ្លើយតបទៅនឹងការគិតថា មានមនុស្សជាច្រើននៅប្រទេសអាម៉េរិកកំពុងតែវិវក់នឹងភាពស្រវឹងយ៉ាងខ្លាំង នាកាលនោះ។ នៅឆ្នាំ១៨៦៩ លោកគ្រូ ថូម៉ាស ប្រេមវ៉ែល វ៉ូលឆ៍ (Thomas Bramwell Welch) ដែលជាគ្រូគង្វាលក្រុមជំនុំវ៉េសស្លៀន (Wesleyan) បានរកឃើញមធ្យោបាយមួយក្នុងការរំងាស់ទឹកទំពាំងបាយជូរដែលអាចទុកវាឲ្យបានយូរ ដែលការនោះបានរៀបរៀងផ្លូវសម្រាប់ក្រុមជំនុំជាច្រើននៅឯប្រទេសអាម៉េរិកក្នុងការគ្រាប់តាមច្បាប់ថ្មីរបស់ពួកគាត់ទាក់ទងនឹងការប្រើប្រាស់ទឹកទំពាំងបាយជូរដែលមិនមានជាតិអាល់កុលក្នុងពិធីលៀងព្រះអម្ចាស់។ ការផ្លាស់ប្តូរទេវវិទ្យាមួយនេះក៏បានជះឥទ្ធិពលលើនយោបាយនៅប្រទេសអាម៉េរិកផងដែរ ដ្បិតនៅឆ្នាំ១៩១៩គេបានចេញវិសោធនកម្មទី១៨ (18th Amendment) ដោយហាមប្រាមការលក់ជូរស្រាដែលអាចនាំឲ្យស្រវឹង។ ចលនាមួយនេះមានឥទ្ធិពលខ្លាំងណាស់ ខ្លាំងរហូតដល់ថ្នាក់មានគ្រូគង្វាលចាប់ផ្តើមបង្រៀនថា ស្រាដែលព្រះយេស៊ូវបានធ្វើ ហើយនឹងទទួលទានគឺជាស្រាដែលមិនមានសារធាតុអាល់កុលក្នុងវាទេ ហើយពួកគាត់ក៏យកសេចក្តីបង្រៀនដ៏ច្បាស់លាស់នៃព្រះបន្ទូល ហើយបត់បែនឲ្យស៊ីគ្នានឹងគោលគំនិតរបស់ខ្លួនវិញ។

# ផឹកឬអត់?

មានមនុស្សជាច្រើនបានប្រកែកថា ដោយសារមានមនុស្សជាច្រើនផឹកស្រាហួសកម្រិតពេក ដូច្នេះគ្រីស្ទបរិស័ទ មិនគួរផឹកឡើយ។ ប៉ុន្តែ តើឲ្យយើងរាវរកភស្តុតាងដោយរបៀបណា ដើម្បីបង្ហាញឲ្យដឹងថា មានភាគរយមនុស្សច្រើនជាងកាលនោះដែលផឹកស្រាហួសហេតុពេក បើប្រៀបធៀបនឹងពេលឥឡូវៗនេះ? ព្រះគម្ពីរបានលើកឡើងយ៉ាងច្បាស់ ហើយក៏បានបង្ហាញយ៉ាងច្បាស់ផងដែរថា ការផឹកជ្រុលដល់ស្រវឹងគឺជាបញ្ហានៅកាលនោះ ហើយក៏នឹងនៅបន្តជាបញ្ហាដល់ឥឡូវនេះផងដែរ។ ប៉ុន្តែ ដូចដែលរាល់អ្វីៗដែលព្រះជាម្ចាស់បានប្រទានមកយើងក្នុងនាមជាអំណោយទាន ក៏យើងនឹងនៅបន្តរករបៀបក្នុងការបង្ខូចវា ក៏ដូចជាប្រើប្រាស់វាសម្រាប់អំពើអាក្រក់ដែរ។ ប៉ុន្តែ គ្រាន់តែដោយសារ បើមាននរណាម្នាក់យកអ្វីមួយទៅប្រើប្រាស់សម្រាប់អំពើអាក្រក់ នោះមិនមែនមានន័យថា យើងមិនគួរប្រើប្រាស់វានោះទេ។ បើចំណុចនេះគឺជាចំណុចដ៏ពិតមែន នោះព្រះយេស៊ូវនឹងមិនធ្វើឲ្យទឹកក្លាយទៅជាស្រានៅឯកន្លែងមង្គលការឡើយ។ ពីព្រោះមាននរណាម្នាក់អាចទទួលទានស្រានោះបាន ហើយក៏អាចស្រវឹងបានផងដែរ។ ហើយនោះគឺមិនមែនគ្រាន់តែជាស្រាលំៗនោះទេ ប៉ុន្តែជាស្រាយ៉ាងល្អ (យ៉ូហាន ២:១០)។ ប៉ុន្តែ ដូចដែលទាក់ទងនឹងអ្វីច្រើនផ្សេងទៀត ព្រះគម្ពីរបានលើកទឹកចិត្តឲ្យយើងប្រើប្រាស់វាកុំហួសហេតុពេក។ ជាជាងតមទាំងស្រុង ផល

ផ្លែនៃព្រះវិញ្ញាណត្រាស់ហៅឲ្យយើងចេះមានការគ្រប់គ្រងលើខ្លួនឯង ហើយការមានផលផ្លែនោះគឺជាភស្តុតាងដែលបង្ហាញថា ព្រះវិញ្ញាណគង់នៅក្នុងយើង។

សរុបសេចក្តីមក តើគ្រីស្ទបរិស័ទអាចផឹកស្រាបានដែរឬទេ? ចម្លើយគឺ៖ បាន! ហើយយើងខ្ញុំក៏គិតផងដែរថា យើងគួរតែប្រើប្រាស់ស្រានៅពេលដែលយើងធ្វើពិធីលៀងព្រះអម្ចាស់ ដើម្បីឲ្យយើងកាន់តែអាចត្រាប់តាមលំនាំដើមរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានប្រទានមកកាន់យើងក្នុងព្រះបន្ទូលទ្រង់បាន ជាជាងធ្វើតាមនូវច្បាប់ថ្មីដែលមនុស្សបានបង្កើតមក។

មានគេបានមួលបង្កាច់ព្រះយេស៊ូវថា ទ្រង់ជាមនុស្សប្រមឹក ពីព្រោះព្រះអង្គបានផឹកស្រា (ម៉ាថាយ ១១:១៩; លូកា ៧:៣៤)។ តើនរណាជាអ្នកមួលបង្កាច់ទ្រង់? គឺសាសនា។ គឺពួកផារិស៊ី។ គឺសាសនាដែលបានបង្កើតវិន័យសម្រាប់ឲ្យមនុស្សត្រាប់តាម ហើយហៅឈ្មោះគេអាក្រក់ៗ ពេលដែលគេមិនត្រាប់តាមវិន័យដែលខាងពួកសាសនាបានបង្កើត។ អស់អ្នកណាដែលជឿថា គ្រីស្ទបរិស័ទមិនគួរទទួលទានភេសជ្ជៈដែលមានជាតិអាល់កុល ក៏នឹងមិនមានផ្លូវគេចចេញពីសេចក្តីពិតមួយនេះដែរ៖ ព្រះយេស៊ូវមិនគ្រាន់តែផឹកស្រាប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គថែមទាំងធ្វើឲ្យមានស្រា ដើម្បីឲ្យអ្នកដទៃអាចផឹកបានផងដែរ។ ព្រះជាម្ចាស់បានបង្កើតស្រាសម្រាប់ឲ្យយើងផឹក និងមានអំណរសប្បាយក្នុងវា។

# សំណួរ

តើមានពេលណាដែលគ្រីស្ទបរិស័ទមិនគួរទទួលទានស្រាដែរឬទេ?

មាន! យើងត្រូវតែប្រើប្រាស់ប្រាជ្ញារបស់យើងក្នុងគ្រប់ពេលទាំងអស់។ ប្រសិនបើសតិសម្បជញ្ញៈដ៏ទន់ខ្សោយរបស់លោកអ្នកថ្កោលទោសលោកអ្នក នោះលោកអ្នកមិនគួរទទួលទានស្រាឡើយ ឬក៏បើការដែលលោកអ្នកទទួលទានស្រានឹងធ្វើឲ្យសតិសម្បជញ្ញៈរបស់នរណាម្នាក់ក្រៀមក្រំ នោះលោកអ្នកក៏មិនគួរទទួលទានស្រាដែរ (១កូរិនថូស ៨:១០-១២; ១០:២៨-២៩)។ ក្នុងព្រះគ្រីស្ទ យើងមានសេរីភាព—ដ្បិតជីវិតវិសេសជាងការស៊ីផឹកទៅទៀត។

ខាងក្រោមនេះគឺជាសំណួរមួយចំនួនដែលលោកអ្នកគួរតែសួរខ្លួនឯងមុនចាប់ផ្ដើមផឹក៖

## ១. ហេតុអ្វីបានជាខ្ញុំចង់ផឹកភេសជ្ជៈដែលមានជាតិអាល់កុល?

តើខ្ញុំកំពុងតែផឹកស្រា ដើម្បីបំភ្លេចទុក្ខកង្វល់ ឬភាពឈឺចាប់ ឬដើម្បីឲ្យស្រវឹង? បើដូច្នោះមែន នោះខ្ញុំមិនគួរផឹកទេ។ តើខ្ញុំកំពុងតែផឹកស្រា ដើម្បីជាការបង្ហាញពីចិត្តអរព្រះគុណ ដោយសារព្រះអង្គបានផ្គត់ផ្គង់? បើដូច្នោះមែន នោះចូរផឹកចុះ។ យើងមិនគួរផឹកស្រា ដើម្បីឲ្យគ្រាន់តែអាចចូលចុះចំណោមគេក្នុងលោកីយ៍

នេះឡើយ។ រាល់អ្វីៗដែលយើងប្រព្រឹត្តឡើង គឺយើងគួរប្រព្រឹត្តឡើងនៅក្នុងជំនឿ ព្រោះបើមិនដូច្នោះទេ នោះមានន័យថា យើងកំពុងធ្វើបាបហើយ (រ៉ូម ១៤:២៣)។

## ២. តើខ្ញុំបានធ្លាប់ប្រព្រឹត្តបាបទាស់នឹងព្រះជាម្ចាស់នាពេលមុនៗ ដែលខ្ញុំធ្លាប់បានផឹករហូតដល់ស្រវឹងដែរឬទេ?

បើខ្ញុំធ្លាប់មានរឿងអតីតជាច្រើនដែលបានកើតឡើងដោយសារខ្ញុំស្រវឹងស្រា នោះដាច់ខាតខ្ញុំត្រូវតែប្រើប្រាស់

ប្រាជ្ញា និងការគ្រប់គ្រងលើខ្លួនឯង ដោយមានចិត្តចង់ផ្គាប់ព្រះទ័យព្រះជាម្ចាស់ជាជាងចង់ផឹកស្រា។ ព្រះជាម្ចាស់បានបង្គាប់យើងយ៉ាងច្បាស់លាស់ហើយថា ទ្រង់មិនសព្វព្រះទ័យឲ្យយើងស្រវឹងស្រានោះទេ។ ហើយបើដូច្នោះមែន នោះទំនងជាការដ៏ល្អប្រសើរណាស់បើខ្ញុំមិនផឹកតែម្តង ដើម្បីកុំឲ្យខ្ញុំធ្លាក់ក្នុងការល្បួងដោយផឹករហូតដល់ស្រវឹងជោកខ្លួន។ អំពើបាបគឺជារឿងដ៏កាចសហាវណាស់ ហេតុដូច្នេះហើយបានជាយើងមិនគួរលក់ព្រលឹងយើងដោយប្តូរនឹងស្រាមួយកែវជាដាច់ខាត។ ប៉ុន្តែ វាក៏ជារឿងដ៏សំខាន់មួយត្រង់ថា លោកអ្នកមិនគួរថ្កោលទោសអស់អ្នកដែលផឹកស្រា ដោយគ្រាន់តែពឹងផ្អែកលើចំណុចថា ខ្លួនមិនផឹក (១ធីម៉ូថេ ៤:៣; កូឡូស ២:១៦-២៣)។

## ៣. តើខ្ញុំមានទម្លាប់ក្នុងការផឹកស្រាច្រើនពេកពីមុនៗដែរឬទេ?

លក្ខណសម្បត្តិមួយរបស់អ្នកត្រួតត្រាគឺថា គាត់មិនគួរ *«ចំណូលស្រា»* ឡើយ (ទីតុស ១:៧)។ លោកអ្នកមិនគួរឲ្យអ្នកផ្សេងមានគំនិតមកកាន់លោកអ្នកថាជា

មនុស្សប្រមឹកនោះឡើយ ទោះបើលោកអ្នកមិនស្រវឹងពេលផឹកច្រើនក៏ដោយ។ ការផឹកស្រាគឺគួរជាអ្វីមួយដែលយើងធ្វើឡើងដោយមានភាពរីករាយអរសប្បាយ មិនមែនជាអ្វីមួយដែលមានការត្រួតត្រាលើលោកអ្នកឡើយ។ ដូច្នេះ បើលោកអ្នកជាបុគ្គលម្នាក់ដែលផឹកច្រើនពេក នោះលោកអ្នកគួរតែចាប់ផ្ដើមកាត់បន្ថយការផឹក ឬក៏ឈប់ផឹកទាំងស្រុងតែម្ដងទៅ។ ចូរទូលសូមឲ្យព្រះជាម្ចាស់ជួយលោកក្នុងការអនុវត្តការគ្រប់គ្រងលើខ្លួនឯង។

## ៤. បើខ្ញុំផឹកស្រា តើសតិសម្បជញ្ញៈរបស់ខ្ញុំនឹងថ្កោលទោសខ្ញុំដែរឬទេ?

ទំនងជាលោកអ្នកធ្លាប់ទទួលបានការបង្រៀនជាយូរយាណាស់មកហើយថា ការដែលគ្រីស្ទបរិស័ទទទួលទានគ្រឿងស្រវឹងគឺជារឿងមិនត្រឹមត្រូវទេ ហើយថា បើលោកអ្នកផឹកស្រាសព្វថ្ងៃនេះ នោះសតិសម្បជញ្ញៈរបស់លោកអ្នកនឹងថ្កោលទោសលោកអ្នកជាមិនខាន។ លោកអ្នកមិនគួរផឹកស្រាឡើយ។ វាមិនមែនជាការដែលបង្ហាញថា លោកអ្នកមានប្រាជ្ញាទេ បើលោកអ្នកធ្វើនូវអ្វីដែលទាស់ប្រឆាំងនឹងសតិសម្បជញ្ញៈរបស់ខ្លួន។ សាវ័ក ប៉ុល បានសរសេរក្នុងកណ្ឌគម្ពីររ៉ូម ១៤:១៤ ដូចតទៅ៖ *«ខ្ញុំដឹង ហើយក៏ជឿពិត ដោយនូវព្រះអម្ចាស់យេស៊ូវថា គ្មានអ្វីស្មោកគ្រោកដោយខ្លួនឯងទេ គឺស្មោកគ្រោកដល់តែអ្នកណា ដែលជឿថារបស់នោះស្មោកគ្រោកប៉ុណ្ណោះ»*។ បើលោកអ្នកទទួលទានគ្រឿងស្រវឹងនៅពេលដែលខ្លួនគិតថាមិនគួរទទួលទាន នោះជាអំពើបាប ព្រោះលោកអ្នកមិនមែនកំពុងតែទទួលទានគ្រឿងស្រវឹងក្នុងជំនឿ។ ដូចដែលសាវ័ក ប៉ុល បានលើកឡើងក្នុងខ២២ និង២៣៖ *«អ្នកឯងមានជំនឿយ៉ាងណា ចូរជឿយ៉ាងនោះតែម្នាក់ឯងនៅ*

*ចំពោះព្រះចុះ មានពរហើយ អ្នកណាដែលមិនកាត់ទោសខ្លួនឯង ក្នុងការដែលខ្លួនរាប់ថាធ្វើបាន តែបើអ្នកណាបរិភោគទាំងសង្ស័យ នោះមានទោសហើយ ពីព្រោះមិនបានបរិភោគដោយជំនឿ ដ្បិតការទាំងប៉ុន្មានដែលធ្វើដោយឥតមានជំនឿ នោះសុទ្ធតែជាបាបទាំងអស់ហើយ»*។

## ៥. តើការទទួលទានគ្រឿងស្រវឹងនឹងនាំឲ្យខ្ញុំធ្លាក់ល្បួងមែនឬ?

ជាទូទៅ ក្នុងលោកីយ៍នេះ ការផឹកស្រាតែងតែពាក់ព័ន្ធគ្នាជាមួយនឹងអំពើបាបផ្សេងៗ ពីព្រោះពេលដែលពួកលោកីយ៍ទទួលទានស្រា ការស្រវឹងតែងតែនាំឲ្យបុគ្គលដែលស្រវឹងនោះទៅប្រព្រឹត្តអំពើបាបបន្ថែមទៀត។ ក្នុងនាមជាគ្រីស្ទបរិស័ទ ព្រះជាម្ចាស់បានត្រាស់ហៅយើងឲ្យធ្វើជាស្មរបន្ទាល់ល្អក្នុងចំណោមអ្នកមិនជឿ ហើយឲ្យរស់នៅក្នុងលក្ខណៈឥតមានគេអាចបន្ទោសបាន (រ៉ូម ១២:១៨; កូឡុស ៤:៥; ១ធីម៉ូថេ ៣:៧; ភីលីព ២:១៥)។ ការនេះមានន័យថា ការទៅផឹកនៅ KTV គឺមិនមែនជាការល្អទេចំពោះគ្រីស្ទបរិស័ទ ពីព្រោះជាដំបូង ភាគច្រើនអស់អ្នកដែលទៅ KTV គឺមិនមែនគ្រាន់តែទៅផឹកស្រាប៉ុណ្ណោះទេ ប៉ុន្តែក៏ទៅដើម្បីសេពគ្រឿងញៀន និងរួមដំណេកជាមួយនឹងស្រីពេស្យាទៀតផង។ ហើយលោកអ្នកក៏ទំនងអាចនឹងធ្លាក់ទៅក្នុងសេចក្តីល្បួងដោយចង់ប្រព្រឹត្តដូចពួកគេផងដែរ។ *«កុំឲ្យច្រឡំឡើយ ពីព្រោះពួកម៉ាកអាក្រក់តែងនឹងបង្ខូចកិរិយាល្អ»* (១កូរិនថូស ១៥:៣៣)។

ហើយចំណុចទី២ ទោះបើលោកអ្នកមិនបានរួមចំណែកក្នុងអំពើបាបក៏ដោយ ក៏ទំនងអ្នកដទៃ (មិនថាអ្នកជឿ ឬក៏មិនជឿ) អាចនឹងឃើញលោកអ្នកទៅ KTV ហើយគិតថាលោកអ្នកបានប្រព្រឹត្តការទាំងអស់នោះដែរ ហើយការនោះនឹងនាំ

ឲ្យព្រះគ្រីស្ទមានព្រះនាមអាក្រក់ដោយសារយើង។ សាវ័ក ប៉ុល បានសរសេរថា *«តើមិនដឹងថា រូបកាយអ្នករាល់គ្នា ជាអវយវៈរបស់ព្រះគ្រីស្ទទេឬអី? ដូច្នេះ តើខ្ញុំនឹងយកអវយវៈរបស់ព្រះគ្រីស្ទ ឲ្យទៅធ្វើជាអវយវៈរបស់ស្រីសំផឹងវិញឬ? ទេ! មិនត្រូវនោះឡើយ!»*។ ព្រះយេស៊ូវបានធ្វើព័ន្ធកិច្ចជាមួយនឹងស្ត្រីពេស្យា និងអ្នកយកពន្ធ ប៉ុន្តែមិនមែនក្នុងរបៀបដែលអាចមានគេមូលបង្កាច់ថាទ្រង់បានប្រព្រឹត្តការនោះឡើយ (មានតែគេមូលបង្កាច់ថា ហេតុអ្វីបានជាព្រះអង្គទៅធ្វើជាមិត្តនឹងពួកគេអញ្ចឹង សូមអានក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១១:១៩)។ ដូច្នេះ ចូរប្រើប្រាស់ប្រាជ្ញា ហើយកុំដាក់ខ្លួនក្នុងស្ថានភាពនៃកន្លែងណាមួយដែលធ្វើឲ្យលោកអ្នកងាយប្រព្រឹត្តបាប ប៉ុន្តែផ្ទុយពីនោះ៖ *«ចូរឲ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន»* (១ពេត្រុស ៥:៨)។

## ៦. តើការដែលខ្ញុំផឹកនឹងធ្វើឲ្យបងប្អូនរួមជំនឿក្នុងព្រះគ្រីស្ទភ្លាត់ជើងដែរឬទេ?

ចំណុចនេះគឺជាចំណុចដ៏គួរឲ្យស្មុគស្មាញមួយណាស់។ ពីព្រោះយើងមានសេរីភាពនៅក្នុងព្រះគ្រីស្ទ ប៉ុន្តែមានគ្រីស្ទបរិស័ទជាច្រើនបានគិតថា យើងគ្មានសេរីភាពទេ។ យើងគួរតែជ្រើសរើសស្រឡាញ់បងប្អូនរួមជំនឿរបស់យើង ជាជាងជ្រើសរើសយកស្រា។ ការដែលយើងមិនធ្វើឲ្យបងប្អូនយើងណាម្នាក់ភ្លាត់ជើង គឺជាការដែលយើងស្រឡាញ់ពួកគាត់។ ប៉ុន្តែ យើងក៏គួរតែព្យាយាមជួយផ្តល់ព័ត៌មានដល់ពួកគាត់អំពីសេចក្តីពិតផងដែរ ដើម្បីកុំឲ្យពួកគាត់ភ្លាត់ជើងនៅពេលអនាគត។ អ្វីដែលយើងធ្វើក្នុងសេចក្តីស្រឡាញ់ និងជំនឿក្នុងព្រះជាម្ចាស់

គឺជាសេរីភាពរបស់យើង។ ដូចដែលសាវ័ក ប៉ុល បានសរសេរក្នុងកណ្ឌគម្ពីរ រ៉ូម ១៤:២០-២៣៖

*«កុំឲ្យបំផ្លាញការព្រះ ដោយព្រោះតែម្ហូបណានោះឡើយ គ្រប់របស់ទាំងអស់ឈ្មោះថាស្អាតមែន តែរមែងជាអាក្រក់ដល់អ្នកណាដែលបរិភោគដោយប្រទាំងវិញ គួរតែកុំឲ្យបរិភោគសាច់ ឬស្រាទំពាំងបាយជូរ ឬអ្វីដែលនាំឲ្យបងប្អូនអ្នកជំពប់ ឬរវាតចិត្ត ឬធ្វើឲ្យខ្សោយនោះឡើយ អ្នកឯងមានជំនឿយ៉ាងណា ចូរជឿយ៉ាងនោះតែម្នាក់ឯងនៅចំពោះព្រះចុះ មានពរហើយ អ្នកណាដែលមិនកាត់ទោសខ្លួនឯង ក្នុងការដែលខ្លួនរាប់ថាធ្វើបាន តែបើអ្នកណាបរិភោគទាំងសង្ស័យ នោះមានទោសហើយ ពីព្រោះមិនបានបរិភោគដោយជំនឿ ដ្បិតការទាំងប៉ុន្មានដែលធ្វើដោយឥតមានជំនឿ នោះសុទ្ធតែជាបាបទាំងអស់ហើយ»*។

ត្រង់នេះសាវ័ក ប៉ុល កំពុងតែនិយាយទាក់ទងនឹងជំនឿរបស់បងប្អូនក្នុងព្រះគ្រីស្ទ មិនមែនទាក់ទងសេចក្ដីល្បួងនៃការស្រវឹងទេ។ បើការផឹកស្រានឹងបណ្ដាលឲ្យបុគ្គលណាម្នាក់មានការចុះខ្សោយក្នុងជំនឿរបស់គាត់ ព្រោះគាត់ជឿយ៉ាងម៉ឺងម៉ាត់ថា គ្រីស្ទបរិស័ទមិនគួរផឹកទេ នោះយើងក៏មិនគួរផឹកនៅក្បែរគាត់ដែរ។ ប៉ុន្តែ បើគាត់គ្រាន់តែមានសេចក្ដីល្បួងក្នុងការផឹករហូតដល់ស្រវឹង នោះយើងគួរលើកទឹកចិត្តគាត់ ហើយជួយគាត់ក្នុងការអនុវត្តការគ្រប់គ្រងខ្លួនឯង ហើយកុំឲ្យប្រព្រឹត្តបាប។

## ៧. បើអ្នកជិតខាងខ្ញុំដែលមិនមែនជាអ្នកជឿព្រះយេស៊ូវហៅខ្ញុំឲ្យផឹកជាមួយគាត់ តើខ្ញុំគួរធ្វើយ៉ាងម៉េច?

ដូចក្នុងគ្រប់កាលៈទេសៈ យើងត្រូវតែទូលសូមឲ្យព្រះជាម្ចាស់ប្រទានប្រាជ្ញា

មកពីស្ថានសួគ៌ដល់យើងក្នុងការសម្រេចចិត្តដែលនឹងប្រទានសិរីល្អដល់ព្រះគ្រីស្ទ។ ទំនងការចូលរួមពិធីឡើងផ្ទះ ឬក៏ពិធីមង្គលការជាមួយនឹងអ្នកចិត្តខាងរបស់លោកអ្នក ការផឹកស្រាដប ឬក៏ស្រាកំប៉ុងជាមួយនឹងអ្នកជិតខាងរបស់លោកអ្នកអាចនឹងបើកទ្វារសម្រាប់ដំណឹងល្អ ពីព្រោះលោកអ្នកមិនទាន់បានថ្កោលទោសការផឹកស៊ីរបស់អ្នកជិតខាងបែបជាពុទ្ធសាសនានិយមនៅឡើយ (យោងតាមសីល៥ «*សុរាមេរ័យមជ្ជប្បមាទដ្ឋានា វេរមណី*» ដែលប្រែថា «*វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ*»)។ ហើយទំនងតាមរយៈការដែលលោកអ្នកធ្វើជាគំរូនៃការចេះគ្រប់គ្រងខ្លួនឯងពេលដែលលោកអ្នកចូលរួម ដោយមិនផឹកដល់ស្រវឹង នោះលោកអ្នកទំនងអាចជាបើកទ្វារសម្រាប់ដំណឹងល្អ ពេលដែលមានគេសួរអំពីមូលហេតុដែលលោកអ្នកមិនផឹករហូតដល់ស្រវឹង។

ដូចដែលសាវ័ក ប៉ុល បានសរសេរថា «*ដ្បិតទោះបើខ្ញុំមិនជាប់បម្រើអ្នកណាសោះក៏ដោយ គង់តែខ្ញុំបានត្រឡប់ទៅជាអ្នកបម្រើដល់មនុស្សទាំងអស់វិញ ដើម្បីឲ្យបានមនុស្សជាច្រើនទៅទៀត ខ្ញុំបានត្រឡប់ដូចជាសាសន៍យូដា ដល់ពួកសាសន៍យូដា ដើម្បីឲ្យបានពួកយូដា ហើយដូចជានៅក្រោមបន្ទុកក្រឹត្យវិន័យ ដល់ពួកអ្នកដែលនៅក្រោមបន្ទុកក្រឹត្យវិន័យ (តែខ្ញុំមិនមែននៅក្រោមបន្ទុកក្រឹត្យវិន័យទេ) ដើម្បីឲ្យបានពួកអ្នក ដែលនៅក្នុងបន្ទុកក្រឹត្យវិន័យ ហើយដូចជាឥតក្រឹត្យវិន័យដល់ពួកអ្នកដែលគ្មានក្រឹត្យវិន័យ (មិនមែនថាខ្ញុំឥតក្រឹត្យវិន័យរបស់ព្រះទេ គឺខ្ញុំនៅក្នុងក្រឹត្យវិន័យព្រះគ្រីស្ទវិញ) ដើម្បីឲ្យបានពួកអ្នកដែលគ្មានក្រឹត្យវិន័យដែរ ខ្ញុំបានត្រឡប់ដូចជាខ្សោយដល់ពួកអ្នកកម្សោយ ដើម្បីឲ្យបានពួកកម្សោយគឺបានត្រឡប់ជាគ្រប់សណ្ឋានទាំងអស់ ដល់មនុស្សទាំង*

*អស់ ប្រយោជន៍ឲ្យបានសង្គ្រោះដល់អ្នកខ្លះ ដោយសារសណ្ឋានទាំងនោះឯង»* (១កូរិនថូស ៩:១៩-២២)។

ប៉ុន្តែ វាក៏អាចជារឿងមួយដែលថា ការចូលរួមផឹកជាមួយនឹងអ្នកជិតខាងរបស់លោកអ្នកក៏ទំនងមិនមែនជាការធ្វើស្មរបន្ទាល់ល្អផងដែរ ជាពិសេសបើអ្នកជិតខាងរបស់លោកអ្នកផឹករហូតដល់ស្រវឹងញឹកញាប់ពេក។ ពីព្រោះបើដូច្នោះមែន នោះការអញ្ជើញរបស់គាត់គឺជាការអញ្ជើញឲ្យផឹកដល់ស្រវឹង ដែលការនោះមិនស៊ីគ្នានឹងរបៀបដែលព្រះជាម្ចាស់បង្គាប់ឲ្យយើងរស់នៅនោះឡើយ។ ក្នុងករណីនេះ នោះទំនងជាការល្អបើលោកអ្នកបដិសេធការអញ្ជើញរបស់អ្នកជិតខាងរបស់លោកអ្នកឲ្យទៅចូលរួមផឹកជាមួយគាត់ ហើយពេលដែលលោកអ្នកមានឱកាសល្អ នោះចូរពន្យល់ប្រាប់គាត់អំពីមូលហេតុ ប៉ុន្តែពេលដែលគាត់ហៅ លោកអ្នកក៏អាចទៅអង្គុយកំដរគាត់ ដោយយកឱកាសនោះបង្កើតទំនាក់ទំនងឲ្យកាន់តែល្អជាមួយនឹងគាត់។

សំណួរដែលយើងត្រូវសួរខ្លួនឯងគឺ៖ តើការដែលខ្ញុំផឹកនឹងថ្វាយព្រះកិត្តិយសដល់ព្រះគ្រីស្ទ ហើយនឹងបើកទ្វារក្នុងការផ្សាយដំណឹងល្អដល់អ្នកជិតខាងរបស់ខ្ញុំដែរឬទេ? ឬក៏តើការដែលខ្ញុំផឹកនឹងបង្ខូចព្រះនាមរបស់ព្រះគ្រីស្ទ ហើយបិទទ្វារក្នុងការផ្សាយដំណឹងល្អ? ចូរអធិស្ឋានទូលសូមប្រាជ្ញាពីស្ថានសួគ៌ ខណៈពេលដែលលោកអ្នកព្យាយាមថ្វាយព្រះកិត្តិយសទៅកាន់ព្រះគ្រីស្ទក្នុងកាលៈទេសៈបែបនោះ។ ដូចដែលសាវ័ក យ៉ាកុប បានសរសេរថា *«តែបើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ ដែលទ្រង់ប្រទានដល់មនុស្សទាំងអស់ដោយសទ្ធា ឥតបន្ទោសផង នោះទ្រង់នឹងប្រទានឲ្យ»* (យ៉ាកុប ១:៥)។

ការផឹក ឬក៏ការមិនផឹកគឺមិនពាក់ព័ន្ធនឹងសេចក្ដីសង្គ្រោះនោះឡើយ។ យើងមិនគួរថ្កោលទោសអ្នកដែលផឹក ឬក៏អ្នកដែលមិនផឹកនោះទេ។

---

យើងខ្ញុំនឹងបញ្ចប់ដោយលើកឡើងនូវសម្រង់សម្ដីរបស់សាវ័ក ប៉ុល ដែលតាមរយៈព្រះវិញ្ញាណបរិសុទ្ធ គាត់បានប្រកាសអំពីសេរីភាពរបស់យើងក្នុងព្រះគ្រីស្ទ ឲ្យយើងស៊ី និងផឹកនូវអ្វីដែលយើងចង់ ដើម្បីថ្វាយសិរីល្អដល់ព្រះជាម្ចាស់៖

*«បើខ្ញុំទទួលទានដោយអរព្រះគុណ នោះតើហេតុអ្វីបានជាគេប្រកាន់ទោសខ្ញុំ ដោយព្រោះរបស់ដែលខ្ញុំបានអរព្រះគុណរួចហើយនោះ ដូច្នេះ ទោះបើស៊ី ឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់សម្រាប់ចម្រើនសិរីល្អដល់ព្រះចុះ»* (១កូរិនថូស ១០:៣០-៣១)។

# អានបន្ថែមនៅ៖

ផ្លូវពិត
plovpit.com

# ហើយទាញយកសៀវភៅជា
# ច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com



លោកអ្នកអាចស្តាប់ព្រះគម្ពីរភាសាខ្មែរជាសំឡេង
បានហើយ!

# អស្ចារ្យមែន!

**ទាញយក «ព្រះគម្ពីរជាសំឡេង» នៅ៖**

https://plovpit.com/khmer-audio-bible/